# ឯកឧត្តមកិត្តិសេង្ឋាបណ្ឌិត ចម ប្រសិទ្ធ ដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំលើសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តង់ដារកម្ពុជា នៅក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា



រដ្ឋសភាបានអនុម័តទាំងស្រុងលើសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីស្តង់ដារកម្ពុជា ក្រោមសំឡេងគាំទ្រ១០៧ លើសមាជិករដ្ឋសភា១០៩រូប ដែលបានចូលរួមសម័យប្រជុំលើកទី១០ នីតិកាលទី៥។

កិច្ចប្រជុំពេញអង្គរដ្ឋសភា នាព្រឹកថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨នេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា ដោយមានការចូលរួមពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងមានសមាជិកសភាចូលរួមប្រមាណ១០៩រូប ដើម្បីពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ចំនួន៣ ក្នុងនោះរួមមាន៖

១៖ សេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា,

២៖ សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការងារ និង

៣៖ សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីស្តង់ដារកម្ពុជា។



ច្បាប់ស្តីពីស្តង់ដារកម្ពុជា ដែលត្រូវធ្វើវិសោធនកម្មនាពេលនេះ រួមមាន៖ មាត្រា៣ មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១២ ចំណងជើងនៃជំពូកទី៤ មាត្រា១៦ មាត្រា១៩ មាត្រា២៦ មាត្រា៥០ មាត្រា៥១ មាត្រា៥២ មាត្រា៥៣ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ មាត្រា៥៩ មាត្រា៦៥ មាត្រា៦៦ មាត្រា៦៧ និងមាត្រា៦៨ ផងដែរ។



គោលបំណង នៃការធ្វើវិសោធនកម្មច្បាប់ស្តីពីស្តង់ដាកម្ពុជា ដែលត្រូវបានដាក់ឱ្យអនុវត្ត ចាប់ពីឆ្នាំ២០០៧ តមកនេះ ត្រូវបាន អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម ផៃ ស៊ីផាន អះអាងថា គឺដើម្បីបំពេញបន្ថែមបទប្បញ្ញត្តិ និងចំណុចសំខាន់មួយចំនួន សំដៅធ្វើការពង្រឹង នូវការអនុវត្តច្បាប់ស្តីពីស្តង់ដាកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ក្នុងការធ្វើឱ្យប្រសើរឡើង នូវគុណភាពផលិតផល សេវាកម្ម និងការគ្រប់គ្រង, បង្កើនប្រសិទ្ធភាពផលិតកម្ម ឱ្យកាន់តែប្រសើរឡើង, ធានាឱ្យធ្វើពាណិជ្ជកម្មមានលក្ខណៈត្រឹមត្រូវ និងងាយស្រួល, បង្កើនការការពារអ្នកប្រើប្រាស់ លើកកម្ពស់សុខមាលភាពសាធារណៈ, ប្រឆាំងរាល់ផលិតផលក្លែងបន្លំ និងគ្មានគុណភាព ដែលបណ្តាលឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាព និងសុវត្ថិភាព មនុស្ស សត្វ និងបរិស្ថាន និងកិច្ចសម្រួលពាណិជ្ជកម្មក្នុងតំបន់ និងអន្តរជាតិ ដោយអនុលោមតាមកិច្ចព្រមព្រៀង របស់អង្គការពាណិជ្ជកម្មពិភពលោក ស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម (World Trade Organization Agreement on Technical Barriers to Trae- WTO/TBT)។



**ខ្លឹមសារសង្ខេប នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មនេះ មានដូចខាងក្រោម៖**

* មាត្រា៣ថ្មី កែសម្រួលនិយមន័យនៃពាក្យ «ស្តង់ដា» ឱ្យស្របតាមនិយមន័យនៃកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក ស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ( WTO/TBT )

* មាត្រា៣ថ្មី មាត្រា៨ថ្មី មាត្រា១២ថ្មី មាត្រា១៦ថ្មី មាត្រា១៩ថ្មី មាត្រា២៦ថ្មី និងមាត្រា៥៩ថ្មី ប្តូរពាក្យ «ស្តងដារបញ្ជា» ជំនួសដោយពាក្យ «បទប្បញ្ញត្តិបច្ចេកទេស» ដើម្បីឱ្យស្របតាមកិច្ចព្រមព្រៀង WTO/TBT

* មាត្រា១៦ថ្មី បង្កើតឱ្យមាននីតិវិធីនៃការកំណត់ «បទប្បញ្ញត្តិបច្ចេកទេស» ស្របតាមកិច្ចព្រមព្រៀង WTO/TBT

* មាត្រា៣ថ្មី មាត្រា៧ថ្មី មាត្រា៨ថ្មី មាត្រា៥០.២ថ្មី មាត្រា៥០.៣ថ្មី មាត្រា៦៥ថ្មី មាត្រា៦៦ថ្មី មាត្រា៦៧ថ្មី និងមាត្រា៦៨ថ្មី ប្តូរពាក្យ អធិការ ជំនួសដោយពាក្យមន្ត្រីអធិការកិច្ច

* មាត្រា៧ថ្មី មាត្រា៨ថ្មី និងមាត្រា៩ថ្មី ផ្តល់នីតិសម្បទា ដល់មន្ត្រីអធិការកិច្ចរបស់វិទ្យាស្ថានស្តង់ដាកម្ពុជាឱ្យទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ និងរៀបចំនីតិវិធី នៃការធ្វើអធិការកិច្ច ដើម្បីពិនិត្យបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ ស្របតាមបទប្បញ្ញត្តិ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងពង្រឹងការអនុវត្តច្បាប់ស្តីពីស្តង់ដាកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់

* មាត្រា៥០ថ្មី ដល់មាត្រា៥៨ថ្មី បង្កើតឱ្យមាន យន្តការនៃការពិន័យអន្តរការណ៍ចំពោះការប្រព្រឹត្តល្មើសទៅនឹងច្បាប់នេះ ដោយក្នុងនោះកែសម្រួលឱ្យមានការបែងចែកកម្រិតដាក់ទោសទណ្ឌដែលជាប្រភេទបទល្មើសតូចតាច ឱ្យទទួលទោសពិន័យជាទឹកប្រាក់ ដោយមិនកំណត់ជាទោសជាប់ពន្ធនាគារលើរាល់ប្រភេទបទល្មើសនោះទេ។

* មាត្រា៣ថ្មី មាត្រា៦ថ្មី មាត្រា៨ថ្មី មាត្រា១១ថ្មី និងមាត្រា៦៨ថ្មី ប្តូរឋានៈ «ប្រធានវិទ្យាស្ថាន» ទៅជា «អគ្គនាយក» តែម្តង ដោយមិនចាំបាច់បញ្ជាក់ថា មានឋានៈស្មើអគ្គនាយកនោះទេ ដើម្បីងាយស្រួលក្នុងការអនុវត្តការងារ ចៀសវាងសាធារណជន មានការយល់ច្រឡំថា វិទ្យាស្ថានស្តង់ដាកម្ពុជា ជាគ្រឹះស្ថានសិក្សាឯកជន មិនមែនជាស្ថាប័នរបស់រាជរដ្ឋាភិបាល និងក៏ដើម្បីឱ្យស្របទៅតាមអង្គភាពស្តង់ដារជាតិ នៃប្រទេសសមាជិកអាស៊ាន